ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ៖ ០១៨/២១ សណ.

**សូមគោរពជូន**

**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**

**កម្មវត្ថុ៖** គោរពស្នើសុំការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ ពន្យាពេលរៀបចំកម្មវិធីអន្តរសាសនាថ្នាក់ជាតិលើកទី០៤ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលគ្រោងនឹងប្រារព្ធធ្វើនាសប្តាហ៍ទី០៣ ខែមករា ឆ្នាំ២០២១ ទៅប្រារព្ធធ្វើនាអំឡុងខែ សីហា ឆ្នាំ២០២១ តាមពេលវេលា និងស្ថានការណ៍សមស្រប។

**យោង៖** - លិខិតលេខ ០០៥/២១ សណ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០២១ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- ចំណារយល់ព្រមដ៏ខ្ពង់ខ្ពស់បំផុត **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ២០២១។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់សូមគោរពជម្រាបជូន **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** មេត្តាជ្រាបថា គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានទទួលការយល់ព្រមជាគោលការណ៍ដ៏ខ្ពង់ខ្ពស់បំផុតពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដើម្បីរៀបចំកម្មវិធីអន្តរសាសនាថ្នាក់ជាតិលើកទី០៤ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

អាស្រ័យដោយកម្មវិធីមមាញឹកជាបន្តបន្ទាប់ និងម្យ៉ាងទៀតពេលវេលាសម្រាប់ការរៀបចំពិធីមានរយៈពេលខ្លី អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សូមគោរពស្នើសុំការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម** ដើម្បី៖
- ពន្យាពេលនៃការរៀបចំកម្មវិធីអន្តរសាសនាថ្នាក់ជាតិលើកទី ០៤ ដែលគ្រោងនឹងប្រារព្ធធ្វើនាសប្តាហ៍ទី០៣ នៃខែមករា ឆ្នាំ២០២១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** និងជា **ប្រធាន គ.ជ.ប.ជ** ទៅប្រារព្ធធ្វើនាអំឡុងខែសីហា ឆ្នាំ២០២១ តាមពេលវេលា និងស្ថានការណ៍សមស្រប ដោយសេចក្តីអនុគ្រោះបំផុត។

អាស្រ័យហេតុដូចបានគោរពជម្រាបជូនខាងលើ សូម **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** មេត្តាពិនិត្យ សម្រេច និង ស្នើសុំមតិដឹកនាំដ៏ខ្ពង់ខ្ពស់។

សូម **សម្តេចក្រឡាហោម** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីនាងខ្ញុំ។

ថ្ងៃ សុក្រ ១៣ ៩ រោច ខែ បុស្ស ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០២១

**អនុប្រធានអចិន្ត្រៃយ៍**

**ជូ-ប៊ុនអេង**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ ០០៤/២១ គជបជ

ខុទ្ទកាល័យសម្តេចតេជោ (វិមានសន្តិភាព)
មុខ លេខ :
ថ្ងៃទី : 12.01.2021
ម៉ោង : 15h00

**សូមគោរពជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី**
**នៃព្រះរាជាណាចក្រកម្ពុជា**

*ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត!*

**កម្មវត្ថុ៖** សូមគោរពស្នើសុំគោលការណ៍អនុញ្ញាត ដើម្បីរៀបចំ**កម្មវិធីអន្តរសាសនា ថ្នាក់ជាតិលើកទី៤ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** តាមពេលវេលាសមស្រប **នាសប្តាហ៍ទី៣ ខែមករា ឆ្នាំ ២០២១។**

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមគោរពជម្រាបជូន **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា៖ ជារៀងរាល់ឆ្នាំគិតចាប់ពីឆ្នាំ២០១៧មក គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) តែងបានសហការជាមួយអ្នកដឹកនាំសាសនាធំៗ ក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីរៀបចំកម្មវិធីអន្តរសាសនា នៅ**សាលមហោស្រព និងពិព័រណ៍កោះពេជ្រ** ដើម្បីបួងសួងឲ្យប្រជាជនកម្ពុជា ក៏ដូចជាប្រជាជនលើពិភពលោក បានសេចក្តីសុខ ជៀសផុតពីការរំលោភបំពាន និងអំពើជួញដូរមនុស្ស ដែលជាទាសភាពសម័យទំនើប។ សារសំខាន់នៃកម្មវិធីនេះ គឺជាការបង្ហាញនូវភាពសុខដុមរមនា នៃសាសនានៅកម្ពុជា ដែលជាតំណាងឲ្យជំនឿ និងការអប់រំផ្លូវចិត្តរបស់មនុស្សជាតិក្នុងពេលដែលប្រឈមនឹងបញ្ហា ឬក្តីបារម្ភផ្សេងៗ ។

នៅឆ្នាំ២០២០ នេះ អាស្រ័យដោយមានការរាតត្បាតនៃជំងឺកូវីដ-១៩ កម្មវិធីនេះត្រូវបានពន្យាពេល ។ ដើម្បីបន្តសកម្មភាពដ៏មានសារសំខាន់នេះ ខ្ញុំសូមគោរពស្នើសុំរៀបចំកម្មវិធីនេះ ក្រោមពាក្យស្លោក «**សូមពិភពលោករួចផុតពីគ្រោះជំងឺរាតត្បាតកូវីដ-១៩ និងអំពើជួញដូរមនុស្ស**» ដោយមានការចូលរួមពីថ្នាក់ដឹកនាំ**ព្រះពុទ្ធសាសនា មូស្លីម កាតូលិក គ្រិស្ត** និងអ្នកមានជំនឿផ្សេងៗទៀត ព្រមទាំងតំណាងអង្គការអន្តរជាតិមួយចំនួនផងដែរ។ ដើម្បីបញ្ចៀសហានិភ័យពីការឆ្លង និងចម្លងមេរោគកូវីដ-១៩ ការរៀបចំនេះ នឹងគោរពស្នើសុំ**ប្រារព្ធធ្វើនៅទីលាន ខាងមុខវត្តបុទុមវត្តី** និង**អនុវត្តតាមវិធានការសុខាភិបាល គឺគោលការណ៍គម្លាតសង្គម** ធ្វើអនាម័យ បាញ់អាល់កុល ដែលពាក់ម៉ាស់ ដោយមានអ្នកចូលរួមប្រមាណ ២០០នាក់ និងពង្រាយតាមគម្លាត យ៉ាងហោចពីរម៉ែត្រពីគ្នា ដោយប្រើរយៈពេលមិនលើសពី ១ម៉ោង អមដោយសុន្ទរកថាប្រមុខរាជរដ្ឋាភិបាល (ឬតំណាង) បើកកម្មវិធីរបាំថ្វាយព្រះពរ និងការបួងសួងព្រមៗគ្នា គ្រប់សាសនា ក្នុងពេលតែមួយ ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** មេត្តាពិនិត្យ និងផ្តល់អនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ ។

សូម **សម្តេចតេជោ នាយករដ្ឋមន្ត្រី** មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់បំផុតពីខ្ញុំ។

ថ្ងៃ សុក្រ ១០កើត ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ មករា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**

**សម្តេចក្រឡាហោម ស ខេង**

13-1-21

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ ៧១២/២០ គជ.

**សូមគោរពជូន**

**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**
**ជាទីគោរពដ៏ខ្ពង់ខ្ពស់។**

អគ្គលេខាធិការដ្ឋានអង្គប្រជុំ
លេខចូល: 951
21-12-20

**កម្មវត្ថុ៖** សូមគោរពស្នើសុំគោលការណ៍អនុញ្ញាត និងហត្ថលេខាដ៏ខ្ពង់ខ្ពស់ លើសំណើសុំគោលការណ៍ទៅ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដើម្បីរៀបចំកម្មវិធីអន្តរសាសនាលើកទី៤ តាមពេលវេលាសមស្រប **នាសប្តាហ៍ទី៣ ខែ មករា ឆ្នាំ២០២១** ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ នាងខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់សូមគោរពជម្រាបជូន **សម្តេចក្រឡាហោម** មេត្តាជ្រាបថា៖ ជារៀងរាល់ឆ្នាំ គិតចាប់ពីឆ្នាំ២០១៧មក គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) តែងបានសហការជាមួយអ្នកដឹកនាំសាសនាធំៗក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីរៀបចំកម្មវិធីអន្តរសាសនា **នៅសាលមហោស្រព និងពិព័រណ៍កោះពេជ្រ** ដើម្បីបួងសួងឲ្យប្រជាជនកម្ពុជា ក៏ដូចជាប្រជាជនលើពិភពលោក បានសេចក្តីសុខ ជៀសផុតពីការរំលោភបំពាន និងអំពើជួញដូរមនុស្ស ដែលជាទាសភាពសម័យទំនើប។ សារសំខាន់នៃកម្មវិធីនេះ គឺជាការបង្ហាញនូវភាពសុខដុមរមនា នៃសាសនានៅកម្ពុជា ដែលជាតំណាងឲ្យជំនឿ និងការអប់រំផ្លូវចិត្តរបស់មនុស្សជាតិ ក្នុងពេលដែលប្រឈមនឹងបញ្ហា ឬក្តីបារម្ភផ្សេងៗ ។

ចូល
លេខ 3024
22-12-20

នៅឆ្នាំ២០២០នេះ អាស្រ័យដោយមានការរាតត្បាតនៃជម្ងឺកូវីដ ១៩ កម្មវិធីនេះត្រូវបានពន្យាពេល ។ ដើម្បីបន្តសកម្មភាពដ៏មានសារសំខាន់នេះ នាងខ្ញុំសូមគោរពស្នើសុំរៀបចំកម្មវិធីនេះ ក្រោមពាក្យស្លោក «សូមពិភពលោករួចផុតពីគ្រោះជម្ងឺរាតត្បាតកូវីដ ១៩ និងអំពើជួញដូរមនុស្ស» ដោយមានការចូលរួមពី ថ្នាក់ដឹកនាំ**ព្រះពុទ្ធសាសនា មូស្លីម កាតូលិក គ្រិស្ត** និងអ្នកមានជំនឿផ្សេងៗទៀត ព្រមទាំងតំណាងអង្គការអន្តរជាតិមួយចំនួនផងដែរ។ ដើម្បីបញ្ចៀសហានិភ័យពីការឆ្លង និងចម្លងមេរោគកូវីដ ១៩ ការរៀបចំនេះ នឹងគោរពស្នើសុំប្រារព្ធធ្វើ **នៅទីលានខាងមុខវត្តបុទុមវត្តី** និងអនុវត្តតាមវិធានការសុខាភិបាល គឺគោលការណ៍គម្លាតសង្គម ធ្វើអនាម័យ បាញ់អាល់កុល ដែល ពាក់ម៉ាស់ ដោយមាន**អ្នកចូលរួម ប្រមាណ ២០០នាក់** និងពង្រាយតាមគម្លាត យ៉ាងហោចពីរម៉ែត្រពីគ្នា ដោយប្រើរយៈពេលមិនលើសពី ១ម៉ោង អមដោយសុន្ទរកថាប្រមុខរាជរដ្ឋាភិបាល (ឬតំណាង) បើកកម្មវិធី របាំថ្វាយព្រះពរ និងការបួងសួងព្រមៗគ្នា គ្រប់សាសនា ក្នុងពេលតែមួយ ។

អាស្រ័យហេតុដូចបានគោរពជម្រាបជូនខាងលើ សូម **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** និងជា **ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** មេត្តាពិនិត្យសំណើសុំនេះ ដើម្បីចុះហត្ថលេខាលើសំណើសុំគោលការណ៍ទៅ **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** ដើម្បីអគ្គលេខាធិការដ្ឋានមានលទ្ធភាពសហការរៀបចំកម្មវិធីនេះតាមពេលវេលាសមស្រប**ក្នុងសប្តាហ៍ទី៣ នៃខែមករា ឆ្នាំ២០២១** បន្ទាប់ពីព្រឹត្តិការណ៍ ២៨ វិច្ឆិកា ត្រូវបានបញ្ចប់ជាស្ថាពរ។

សូម **សម្តេចក្រឡាហោម** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីនាងខ្ញុំ។

ថ្ងៃ ............ ខែ ............ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ១២ ឆ្នាំ២០២០

**អនុប្រធានអចិន្ត្រៃយ៍**

**ជូ ប៊ុនអេង**